សេចក្តីសង្ខេបព័ត៌មាន និងព្រឹត្តិការណ៍សំខាន់ៗប្រចាំខែមីនា របស់និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រួមមានដូចខាងក្រោម៖

### កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០"



១.កាលពីថ្ងៃព្រហស្បតិ៍ ៨ កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែមីនា គ.ស.២០២៥ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០២១-២០៣០ នៅទីស្តីការ ក.ស.ហ.វ.។

### ពិធីសំណេះសំណាលអបអរសាទរខួបទី១១៤ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៥



## ព័ត៌មានថ្មីៗ


កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ..........................១
ពិធីសំណេះសំណាល សូមអាននៅទំព័រ................ ២
កិច្ចប្រជុំក្រុមប្រឹក្សា សូមអាននៅទំព័រ ....................២
កិច្ចប្រជុំបច្ចេកទេស សូមអាននៅទំព័រ...................២
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ..........................៣
វគ្គបណ្តុះបណ្តាលស្តីពី សូមអាននៅទំព័រ................៣
វេទិកាស្តីពី សូមអាននៅទំព័រ................................៤
វគ្គបណ្តុះបណ្តាលស្តីពី សូមអាននៅទំព័រ.................៥
សិក្ខាសាលាផ្សព្វផ្សាយស្តីពី សូមអាននៅទំព័រ..........៥
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ..........................៦
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ..........................៦
សិក្ខាសាលាស្តីពី សូមអាននៅទំព័..........................៦
សិក្ខាសាលាស្តីពី សូមអាននៅទំព័..........................៧
ពិធីសំណេះសំណាល សូមអាននៅទំព័រ..................៧
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ..........................៨
កិច្ចប្រជុំ សូមអាននៅទំព័រ......................................៨
កិច្ចប្រជុំពិនិត្យ សូមអាននៅទំព័រ............................៩
សិក្ខាសាលាផ្សព្វផ្សាយស្តីពី សូមអាននៅទំព័រ..........៩
កិច្ចប្រជុំពិនិត្យ សូមអាននៅទំព័រ............................៩
សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ.............១០
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.......................១០
កិច្ចប្រជុំពិគ្រោះយោបល់ សូមអាននៅទំព័រ...........១១
កិច្ចប្រជុំ សូមអាននៅទំព័រ...................................១១
កិច្ចប្រជុំពិគ្រោះយោបល់ សូមអាននៅទំព័រ...........១២
កិច្ចប្រជុំ សូមអាននៅទំព័រ...................................១២
សិក្ខាសាលាផ្សព្វផ្សាយស្តីពី សូមអាននៅទំព័រ........១៣
កិច្ចប្រជុំថ្នាក់ដឹកនាំ សូមអាននៅទំព័រ..................១៣
កិច្ចប្រជុំ សូមអាននៅទំព័រ...................................១៤
ចូលរួមសន្និបាត សូមអាននៅទំព័រ.......................១៤
កិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ សូមអាននៅទំព័រ..........១៤
កិច្ចប្រជុំ សូមអាននៅទំព័រ...................................១៥
ពិនិត្យនិងវាយតម្លៃ សូមអាននៅទំព័រ...................១៥


© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

Facebook Website Telegram

២.កាលពីថ្ងៃចន្ទ ១២កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែមីនា គ.ស.២០២៥ **លោកស្រី នាន បូនី** អគ្គនាយករង និងជាសមាជិកាក្រុមការងារយេនឌ័រ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អមដោយ មន្ត្រីជំនាញ បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល អបអរសាទរខួបទី១១៤ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៥ ក្រោមប្រធានបទ សិទ្ធិ សមភាព និងភាពអង់អាចចំពោះស្ត្រីនិងក្មេងស្រីគ្រប់រូប ដែលបានរៀបចំឡើងនៅទីស្តីការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោកជំទាវ**។ ពិធីនេះក៏មានការអញ្ជើញចូលរួមពីសំណាក់ លោកជំទាវ ឯកឧត្តម ជាថ្នាក់ដឹកនាំ និងសមាជិក សមាជិកាក្រុមការងារយេនឌ័រ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងមានការចូលរួមពី លោកស្រី អ្នកនាង កញ្ញា ជាតំណាងមកពីអគ្គនាយកដ្ឋាន អង្គភាព មន្ទីរក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៣



៣.កាលពីថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែមីនា គ.ស.២០២៥ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** ដែលបានប្រព្រឹត្តទៅនៅសាលប្រជុំនៃទីស្តីការ **អ.ស.ហ.**។

## កិច្ចប្រជុំបច្ចេកទេស អ.ស.ហ.




៤.កាលពីថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែមីនា គ.ស.២០២៥ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីជំនាញនៃការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុបានចូលរួមកិច្ចប្រជុំបច្ចេកទេស **អ.ស.ហ.** ដើម្បីពិភាក្សាលើរបាយការណ៍អនុវត្តថវិកាប្រចាំឆ្នាំ២០២៤ របស់អង្គភាពក្រោមឱវាទនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ តាម

ប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ កិច្ចប្រជុំនេះក៏មានការអញ្ជើញចូលរួមពីអគ្គនាយកពីគ្រប់និយ័តករក្រោមឱវាទ និងមន្ត្រីជំនាញនៃ អង្គភាពក្រោមឱវាទ **អ.ស.ហ.** ផងដែរ។

## កិច្ចប្រជុំពិភាក្សាលើការអនុវត្តសកម្មភាពទី១



៥.កាលពីថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៥ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម លោកស្រី ថៅ សេដ្ឋចាន់លីដា អនុប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ ន.គ.ស. អមដោយមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំពិភាក្សាលើការអនុវត្តសកម្មភាពទី១ នៃគម្រោងជំនួយបច្ចេកទេសស្តីពីការរៀបចំរបាយការណ៍ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច សម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីតំណាងនៃ និយ័តករសន្តិសុខសង្គម និយ័តករមូលបត្រកម្ពុជា និយ័តករបរធនបាលកិច្ច និយ័តករធានារ៉ាប់រងកម្ពុជា និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ។

## វគ្គបណ្តុះបណ្តាលស្តីពីថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ




៦.កាលពីថ្ងៃចន្ទ ១២កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែមីនា គ.ស២០២៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រាសធុនតូចនិងមធ្យមនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញវគ្គទី១០ដែលប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករគណនេយ្យនិងសវនកម្ម។ **ឯកឧត្តម អគ្គនាយក** បានរំលេចនូវអត្ថប្រយោជន៍មួយចំនួននៃថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រាសធុនតូចនិងមធ្យមនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញរួមមាន ១.ជួយសម្រួលដំណើរការរៀបចំនិងកាត់បន្ថយចំណាយក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សម្គាល់ដោយផ្អែកតាមទម្រង់រួមបែបឌីជីថល និងទិន្នន័យដែលស្របតាមស្តង់ដាគណនេយ្យ ២.ជួយកាត់បន្ថយកំហុសឆ្គងនិង

បង្កើនកម្រិតអនុលោមភាពក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តាមរយៈគោលការណ៍ផ្ទៀងផ្ទាត់អនុលោមភាពដោយស្វ័យប្រវត្តិក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុបែបឌីជីថល ៣.បង្កើនគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុដែលអនុលោមតាមស្តង់ដារដោយផ្អែកតាមវត្តករសាស្ត្រគណនេយ្យរបស់ស្តង់ដាគណនេយ្យអន្តរជាតិនិង ៤.បង្កើនគុណភាពនៃការសម្រេចចិត្តនិងការវិនិយោគ ដោយផ្អែកតាមការវិភាគអនុបាតហិរញ្ញវត្ថុ។

## វេទិកាស្តីពី "ហិរញ្ញវត្ថុសកល និងបណ្តាញបច្ចេកវិទ្យា (GFTN) 2025" នៅទីក្រុងតូក្យូ ប្រទេសជប៉ុន




៧.កាលពីថ្ងៃពុធ ៧កើត-សុក្រ៩កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥-៧ ខែមីនា គ.ស.២០២៥ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ បានចូលរួមវេទិកាស្តីពី "ហិរញ្ញវត្ថុសកលនិងបណ្តាញបច្ចេកវិទ្យា (GFTN) 2025" នៅទីក្រុងតូក្យូ ប្រទេសជប៉ុន។ GFTN គឺជាបណ្តាញសហគមន៍អន្តរជាតិ គោលនយោបាយហិរញ្ញវត្ថុនិងបច្ចេកវិទ្យា ដែលរៀបចំឡើងដើម្បីពិភាក្សាអំពីបច្ចេកវិទ្យា បញ្ញាសិប្បនិម្មិត និងសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងការលើកកម្ពស់ក្រមសីលធម៌បច្ចេកវិទ្យា បញ្ញាសិប្បនិម្មិតនិងដំណោះស្រាយបរិស្ថានដោយបច្ចេកវិទ្យាព្រមទាំងមានការបង្ហាញពីការចាប់ផ្តើមអាជីវកម្ម (Startups) តំណាងពីតំបន់អាស៊ាន អឺរ៉ុប និងក្រុមហ៊ុនអន្តរជាតិនៅជប៉ុន។ ជាពិសេសវេទិកានេះផ្តោតលើការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ ក្នុងបរិបទសេដ្ឋកិច្ចពិភពលោក និងផលប៉ះពាល់ទៅលើវិស័យហិរញ្ញវត្ថុ និងបច្ចេកវិទ្យាថ្មីៗដូចជាបច្ចេកវិទ្យា បញ្ញាសិប្បនិម្មិត សន្តិសុខសាយប័រ ការការពារទិន្នន័យហិរញ្ញវត្ថុ និងឧស្សាហកម្មហិរញ្ញវត្ថុនាពេល អនាគត។

## វគ្គបណ្តុះបណ្តាលស្តីពីថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ



៨.កាលពីថ្ងៃចន្ទ ១២កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែមីនា គ.ស២០២៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រាសធុនតូចនិងមធ្យមនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញវគ្គទី១១ ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃនិយ័តករគណនេយ្យនិងសវនកម្ម។ លោកស្រីអគ្គនាយករងបានរំលេចនូវអត្ថប្រយោជន៍មួយចំនួននៃថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រាសធុនតូចនិងមធ្យមនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ រួមមាន ១.ជួយសម្រួលដំណើរការរៀបចំនិងកាត់បន្ថយចំណាយក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សម្គាល់ដោយផ្អែកតាមទម្រង់រួមបែបឌីជីថល និងទិន្នន័យដែលស្របតាមស្តង់ដាគណនេយ្យ ២.ជួយកាត់បន្ថយកំហុសឆ្គងនិងបង្កើនកម្រិតអនុលោមភាពក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមរយៈគោលការណ៍ផ្ទៀងផ្ទាត់អនុលោមភាពដោយស្វ័យប្រវត្តិក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុបែបឌីជីថល ៣.បង្កើនគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុដែលអនុលោមតាមស្តង់ដាដោយផ្អែកតាមវដ្តករសាស្ត្រគណនេយ្យរបស់ស្តង់ដាគណនេយ្យអន្តរជាតិ និង៤.បង្កើនគុណភាពនៃការសម្រេចចិត្តនិងការវិនិយោគដោយផ្អែកតាមការវិភាគអនុបាតហិរញ្ញវត្ថុ។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល និងនីតិវិធីក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ




៩.កាលពីថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែមីនា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល និងនីតិវិធីក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ (E-Filing) សម្រាប់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិង សវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រី នៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងវត្តមានរបស់តំណាងសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញសរុបចំនួន ៤៥០នាក់។

## កិច្ចប្រជុំពិភាក្សាស្តីពីការគ្រោងរៀបចំទិវាជាតិគណនេយ្យឆ្នាំ២០២៥ លើកទី២



១០.កាលពីថ្ងៃចន្ទ ១២កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែមីនា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានដឹកនាំកិច្ចប្រជុំពិភាក្សាស្ដីពីការគ្រោងរៀបចំវេទិកាជាតិគណនេយ្យឆ្នាំ២០២៥ លើកទី២ នៅការិយាល័យអាគារ ៣៤៥ ដែលមានការចូលរួមពី ប្រធានឬតំណាងក្រុមហ៊ុនគណនេយ្យនិងសវនកម្ម ដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ពី ន.គ.ស.។ កិច្ចប្រជុំនេះមានគោលបំណង ប្រមូលធាតុចូលសំខាន់ៗ និងជំហរនៃការគាំទ្រលើការរៀបចំវេទិកាជាតិគណនេយ្យឆ្នាំ២០២៥ លើកទី២ ឱ្យកាន់តែប្រសើរ។

## កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារវាយតម្លៃរបស់វេទិកាសកល




១១.កាលពីថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែមីនា គ.ស.២០២៥ នៅសណ្ឋាគារ សាន់វ៉េ, ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម លោក លី កុសល អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព អមដោយមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារវាយតម្លៃរបស់វេទិកាសកលស្ដីពីតម្លាភាពនិងការផ្លាស់ប្ដូរព័ត៌មានដើម្បីគោលបំណងពន្ធ ក្នុងទស្សនកិច្ចមកកម្ពុជានិងវាយតម្លៃដល់ទីកន្លែង។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីតំណាងនៃ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ធនាគារជាតិនៃកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និយ័តករបរធនបាលកិច្ច និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

## សិក្ខាសាលាស្តីពី "បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា"



១២.កាលពីថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែមីនា គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម លោក ទឹម សត្យា អនុប្រធាននាយកដ្ឋានទទួលបន្ទុកនាយកដ្ឋានកិច្ចការទូទៅ អមដោយមន្ត្រីជំនាញ ន.គ.ស. បានអញ្ជើញចូលរួមកម្មវិធីសិក្ខាសាលាស្តីពី "បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា" ក្រោមអធិបតីភាព **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច និង **ឯកឧត្តម អ៊ុំ លុយណា** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។ សិក្ខាសាលាដ៏មានសារៈសំខាន់មួយនេះត្រូវបានចូលរួមធ្វើបាឋកថាដោយ **ឯកឧត្តម អ៊ុំ លុយណា** អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## សិក្ខាសាលាស្តីពី "ការវិវត្តថ្មីៗក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា និងវិធានការណ៍ជាយុទ្ធសាស្ត្រពាក់ព័ន្ធ"




១៣.កាលពីថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែមីនា គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម លោក ឈុត វិឆ័យ អនុប្រធានការិយាល័យរដ្ឋបាលនិងបុគ្គលិក អមដោយមន្ត្រីជំនាញ ន.គ.ស. បានចូលរួមកម្មវិធីសិក្ខាសាលាស្តីពី "ការវិវត្តថ្មីៗក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា និងវិធានការណ៍ជាយុទ្ធសាស្ត្រពាក់ព័ន្ធ" ក្រោមអធិបតីភាព **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

## ពិធីសំណេះសំណាលអបអរសាទរខួបអនុស្សាវរីយ៍ លើកទី ១១៤ ទិវាអន្តរជាតិនារី ០៨ មីនា ឆ្នាំ២០២៥



១៤.កាលពីថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែមីនា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំពិធីសំណេះសំណាលអបអរសាទរខួបអនុស្សាវរីយ៍ លើកទី១១៤ ទិវាអន្តរជាតិនារី ០៨ មីនា ឆ្នាំ២០២៥ ក្រោមប្រធានបទ "សិទ្ធិ សមភាព និងភាពអង់អាចចំពោះស្ត្រីនិងក្មេងស្រីគ្រប់រូប" នៅអគារ ៣៤៥ ។ កម្មវិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និង លោកជំទាវ អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង ន.គ.ស. **លោក ជា ចាន់ថា** អគ្គនាយករង ន.គ.ស. និង លោក លោកស្រី អ្នកនាង កញ្ញា ដែលជាមន្ត្រីជានារីទាំងអស់របស់និយ័តករគណនេយ្យនិងសវនកម្ម។

## កិច្ចប្រជុំពិភាក្សាលើព្រឹត្តិបត្រប្រចាំឆ្នាំ២០២៤



១៥.កាលពីថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែមីនា គ.ស.២០២៥ ក្រុមការងារចំពោះកិច្ចបានរៀបចំកិច្ចប្រជុំពិភាក្សាលើព្រឹត្តិបត្រប្រចាំឆ្នាំ២០២៤ របស់និយ័តករគណនេយ្យនិងសវនកម្ម ក្រោមអធិបតីភាពខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាប្រធានក្រុមការងារ ដែលមានការអញ្ជើញចូលរួមពី លោក លោកស្រី ជាអនុប្រធាន និងសមាជិកក្រុមការងារ នៅអគារ ៣៤៥ ទួលគោក។

## កិច្ចប្រជុំរៀបចំផែនការសកម្មភាព និងទិសដៅការងារ ឆ្នាំ២០២៥



១៦.កាលពីថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែមីនា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានចាត់លោកស្រី ថៅ សេដ្ឋចាន់លីដា អនុប្រធាននាយកដ្ឋាននិងមន្ត្រីជំនាញ ចូលរួមកិច្ចប្រជុំរៀបចំផែនការសកម្មភាព និងទិសដៅការងារ ឆ្នាំ២០២៥ ពាក់ព័ន្ធនឹងការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលដឹកនាំកិច្ចប្រជុំដោយ **លោកបណ្ឌិត សោម ផៃ** អគ្គលេខាធិការរងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងមានការអញ្ជើញចូលរួមពីតំណាងនិយ័តករក្រោមឱវាទ អ.ស.ហ. នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## កិច្ចប្រជុំពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (IDP) ឆ្នាំ២០១៥-២០២៥



១៧.កាលពីថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម លោក ណុប សម្បត្តិ អនុប្រធាននាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម និងមន្ត្រីជំនាញបានចូលរួមកិច្ចប្រជុំពិនិត្យ តាមដានវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍ វិស័យឧស្សាហកម្មកម្ពុជា (IDP) ឆ្នាំ២០១៥-២០២៥ ដែលដឹកនាំកិច្ចប្រជុំដោយ លោក ផេង អ៊ី អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានប្រព្រឹត្តទៅនៅសាលប្រជុំនៃទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពីភាតព្វកិច្ចគណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ



១៨.កាលពីថ្ងៃអង្គារ ៥រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែមីនា គ.ស២០២៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកាតព្វកិច្ចគណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់សហគ្រាសនិងអង្គភាពមិស្វែងរកប្រាក់ចំណេញនៅតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករ គណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃនិយ័តករគណនេយ្យនិងសវនកម្ម។ នាឱកាសនោះផងដែរ **ឯកឧត្តមអគ្គនាយក** បានលើកឡើងថា ក្នុងនាមនិយ័តករគណនេយ្យននិងសវនកម្ម មិនចង់អនុវត្តពិន័យអន្តរការណ៍លើសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញណាមួយទេ ប៉ុន្តែស្នើសុំឱ្យសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញទាំងអស់ចូលរួមក្នុងការបង្កើតប្រព័ន្ធគណនេយ្យមួយដែលរឹងមាំ មានតម្លាភាព និងអាចជឿទុកចិត្តបាន។

## កិច្ចប្រជុំពិនិត្យលើការរៀបចំសេចក្តីព្រាងសារាចរសម្រាប់ការអនុវត្តការបង់ចំណូលសារពើពន្ធតាមមូលដ្ឋានបង្គរ




១៩.កាលពីថ្ងៃអង្គារ ៥រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែមីនា គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម, លោក ហេង សំណាង ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈ អមដោយមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានចូលរួមកិច្ចប្រជុំពិនិត្យលើការរៀបចំសេចក្តីព្រាងសារាចរសម្រាប់ការអនុវត្តការបង់ចំណូលសារពើពន្ធ តាមមូលដ្ឋានបង្គរ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រោមការដឹកនាំរបស់ លោក ជា វណ្ណារ័ត្ន ប្រធាននាយកដ្ឋានចំណូលថវិកានៃអគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានការចូលរួមពីតំណាងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមប្រព័ន្ធអនឡាញ។

## សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនសាស្ត្រាចារ្យនិងនិស្សិត នៃសាខាសាកលវិទ្យាល័យមៀលប្រាយ



២០.កាលពីថ្ងៃអង្គារ ៥រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែមីនា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សហការជាមួយសាខាសាកលវិទ្យាល័យបៀលប្រាយ ខេត្តព្រះសីហនុ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនសាស្ត្រាចារ្យនិងនិស្សិត នៃសាខាសាកលវិទ្យាល័យបៀលប្រាយ ខេត្តព្រះសីហនុ ក្រោមអធិបតីភាព **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមពី លោកស្រី សេង សុភា នាយិកាសាខាសាកលវិទ្យាល័យបៀលប្រាយ ខេត្តព្រះសីហនុ និងលោកស្រី សារ៉ុធ ដាលី នាយកប្រតិបត្តិ នៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម លោកគ្រូ អ្នកគ្រូ និងសិស្ស និស្សិត ចំនួន១៥៥នាក់។

## សិក្ខាសាលាស្តីពីប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ (KHQR)




២១.កាលពីថ្ងៃព្រហ.៧រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែមីនា គ.ស.២០២៥ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីជំនាញនៃការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុបានចូលរួមសិក្ខាសាលាស្តីពីប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ (KHQR) ក្នុងឱកាសអបអរសាទរខួបលើកទី៤៥ នៃការដាក់ឱ្យចរាចរប្រាក់រៀលសាឡើងវិញ (២០ មីនា ១៩៨០-២០ មីនា ២០២៥) នៅវិមានរដ្ឋសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** អនុប្រធានទី១ នៃរដ្ឋសភា ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា** និងមានការអញ្ជើញចូលរួមពី សមាជិក សមាជិកាព្រឹទ្ធសភាព រដ្ឋសភា តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិនានានៅកម្ពុជា។

## កិច្ចប្រជុំពិគ្រោះយោបល់លើ "សេចក្តីព្រាងប្រកាសស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យល្បែងពាណិជ្ជកម្ម"



២២.កាលពីថ្ងៃព្រហស្បតិ៍ ៧រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែមីនា គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពស់ខ្ពង់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម, លោក ណុប សម្បត្តិ អនុប្រធាននាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម និងប្រធានការិយាល័យអាជ្ញាបណ្ណ បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើ "សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីបែបបទ និងលក្ខខណ្ឌនៃការទទួល ស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យល្បែងពាណិជ្ជកម្ម" នៅសាលប្រជុំនៃអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ក្នុងគោលបំណងប្រមូលធាតុចូលបន្ថែមលើសេចក្តីព្រាងប្រកាសឱ្យកាន់តែពេញលេញ គ្រប់ជ្រុងជ្រោយ និងមានសង្គតិភាពជាមួយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## កិច្ចប្រជុំបិទស្តីពីការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រង ការអនុវត្តចំណូល-ចំណាយថវិកា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងការិបរិច្ឆេទ ២០២២-២០២៣



២៣.កាលពីថ្ងៃព្រហស្បតិ៍ ៧រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែមីនា គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យ និងសវនកម្ម លោក ទឹម សត្យា អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការទូទៅ អមដោយប្រធានការិយាល័យ បានអញ្ជើញចូលរួមកិច្ចប្រជុំបិទស្តីពីការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រង ការអនុវត្តចំណូល-ចំណាយថវិកា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងការិបរិច្ឆេទ ២០២២-២០២៣ និងឆ្នាំពាក់ព័ន្ធ ជាមួយអគ្គាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះដឹកនាំដោយ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. និង **ឯកឧត្តម ឆាយ រតនៈ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គាធិការ នៃអគ្គាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីជាមួយតំណាងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា



២៤.កាលពីថ្ងៃព្រហស្បតិ៍ ៧រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែមីនា គ.ស.២០២៥ នៅបន្ទប់ប្រជុំធំ ន.គ.ស. **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីជំនាញនិងទីប្រឹក្សាបច្ចេកទេស នៃ ន.គ.ស. បានជួបប្រជុំពិគ្រោះយោបល់ទ្វេភាគីជាមួយតំណាងវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ប្រធានគណៈកម្មការស៊ើបអង្កេតនិងវិន័យ និងលេខាធិការ នៃវ.គ.ស.ក.។ កិច្ចប្រជុំនេះ មានគោលបំណងដើម្បីពិគ្រោះយោបល់លើ "សេចក្តីព្រាងនីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការស៊ើបអង្កេត និងដាក់ទណ្ឌកម្មវិន័យរបស់ វ.គ.ស.ក."។

## កិច្ចប្រជុំ ដើម្បីពិនិត្យ ពិភាក្សា និងកែសម្រួលលើសេចក្តីព្រាង



២៥.កាលពីថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែមីនា គ.ស.២០២៥ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យ ពិភាក្សា និងកែសម្រួល លើ៖១-សេចក្តីព្រាងក្របខណ្ឌកាត់បន្ថយការរាយការណ៍ហិរញ្ញវត្ថុកម្ពុជា និង២-សេចក្តីព្រាងប្លង់គណនេយ្យសម្រាប់សហគ្រាស/អង្គភាពធុនតូចនិងមធ្យម ដោយមានការចូលរួមពីទីប្រឹក្សាបច្ចេកទេសនៃ ន.គ.ស. និងមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស នៅអគារ ៣៤៥។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ" ក្នុងវិស័យល្បែងពាណិជ្ជកម្ម ជូនប្រតិបត្តិករល្បែងផ្សងសំណាង, កម្មសិទ្ធករ និង/ឬប្រតិបត្តិករកាស៊ីណូ និងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍



២៦.កាលពីថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែមីនា គ.ស.២០២៥ **និយ័តករគណនេយ្យនិងសវនកម្ម** នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី **"កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ"**

**ក្នុងវិស័យល្បែងពាណិជ្ជកម្ម ជូនប្រតិបត្តិករល្បែងផ្សងសំណាង, កម្មសិទ្ធករ និង/ឬប្រតិបត្តិករកាស៊ីណូ និងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍។** សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និង**ឯកឧត្តមឧត្តមសេនីយ៍ឯក សៀង សេន អគ្គលេខាធិការរង** នៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា អមដោយថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ន្ត្រីនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ព្រមទាំងវត្តមានតំណាងប្រតិបត្តិករល្បែងផ្សងសំណាង, កម្មសិទ្ធករ និង/ឬប្រតិបត្តិករកាស៊ីណូ និងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ចំនួន២៦០នាក់។

## កិច្ចប្រជុំថ្នាក់ដឹកនាំ លើសេចក្ដីព្រាងប្រកាសស្ដីពីការគ្រប់គ្រងគុណភាពសវនកម្មនិងការអះអាង




២៧.កាលពីថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែមីនា គ.ស.២០២៥ នៅបន្ទប់ប្រជុំធំ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំ លើសេចក្ដីព្រាងប្រកាសស្ដីពីការគ្រប់គ្រងគុណភាពសវនកម្មនិងការអះអាង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ ន.គ.ស.។ កិច្ចប្រជុំនេះ មានគោលបំណងគោរពរាយការណ៍អំពីវឌ្ឍនភាព លើកយោបល់ និងស្នើសុំគោលការណ៍សម្រេចលើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តខាងលើ ដើម្បីបន្តនីតិវិធីប្រកបដោយប្រសិទ្ធភាព។

## កិច្ចប្រជុំជាមួយតំណាងសមាគមគណនេយ្យករជំនាញ (ACCA)



២៨.កាលពីថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែមីនា គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម, **លោកស្រី នាន បូនី** អគ្គនាយករង អមដោយមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានដឹកនាំកិច្ចប្រជុំជាមួយតំណាងសមាគមគណនេយ្យករជំនាញ(ACCA) តាមប្រព័ន្ធអនឡាញ ដើម្បីជជែកពិភាក្សាអំពី "ការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល (Train-the-Trainer Program) សម្រាប់ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា" ។

## ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារ ប្រចាំឆ្នាំ២០២៤ របស់សមាគមអគ្គិសនីជនបទ




២៩.កាលពីថ្ងៃពុធ ១៣ រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែមីនា គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម, លោក ហេង សំណាង ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈ អមដោយ មន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានចូលរួមកិច្ចប្រជុំពិភាក្សាលើវឌ្ឍនភាពក្នុងការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គាំទ្រការអនុវត្តប្រកាសស្តីពីការអនុវត្តកិច្ចបញ្ជិកាគណនេយ្យនៃគណនីត្រូវសង សន្និធិ និងឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់រូបិយបណ្ណបរទេស ក្រោមការដឹកនាំដោយ លោក ជា សុជាតិ ប្រធាននាយកដ្ឋានគោលការណ៍គណនេយ្យ និងការអនុវត្តថវិកា នៃអគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានការចូលរួមពីតំណាងអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងនាយកដ្ឋានចំណូលថវិកា នៃអគ្គនាយកដ្ឋានរតនាគារជាតិ តាមប្រព័ន្ធអនឡាញ។

## កិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ (High Level Kick-Off) លើគម្រោងជំនួយបច្ចេកទេសស្តីពីការរៀបចំ "របាយការណ៍ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចសម្រាប់វិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ"



៣០.កាលពីថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែមីនា គ.ស.២០២៥ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងក៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃ ន.គ.ស. បានអញ្ជើញចូលរួមកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ (High Level Kick-Off) លើគម្រោងជំនួយបច្ចេកទេសស្តីពីការរៀបចំ "របាយការណ៍ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចសម្រាប់វិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ" ក្រោមអធិបតីភាព **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរសេវា

ហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។ កិច្ចប្រជុំនេះក៏មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ នៃនិយ័តករក្រោមឱវាទ អ.ស.ហ. តំណាងនៃការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (AMRO) និងតំណាងនៃវិទ្យាស្ថានទីផ្សារមូលធនកូរ៉េ (KCMI)។

## កិច្ចប្រជុំស្តីពីការចែករំលែកព័ត៌មានស្តីពី "ហិរញ្ញវត្ថុសកល និងបណ្តាញបច្ចេកវិទ្យា (GFTN) 2025"




៣១.កាលពីថ្ងៃព្រហស្បតិ៍ ១៤ រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែមីនា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំស្តីពីការចែករំលែកព័ត៌មានស្តីពី "ហិរញ្ញវត្ថុសកល និងបណ្តាញបច្ចេកវិទ្យា (GFTN) 2025" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ លោកស្រី អគ្គនាយករង លោក លោកស្រីអនុប្រធាននាយកដ្ឋាន និងមន្ត្រីនៃ ការិយាល័យព័ត៌មានវិទ្យា នៃនាយកដ្ឋានកិច្ចការទូទៅ គោលបំណងនៃបទបង្ហាញនេះគឺដើម្បីចែករំលែកបទពិសោធន៍ព័ត៌មានដែលទទួលបានពីការចូលរួម វេទិកាកាលពីថ្ងៃទី៥-៧ ខែមីនា ឆ្នាំ២០២៥ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ដើម្បីចូលរួមចំណែកនៅ ក្នុងការអភិវឌ្ឍន៍ស្ថាប័នរបស់ ន.គ.ស. ផងដែរ។

## ពិនិត្យនិងវាយតម្លៃក្នុងការទទួលស្គាល់សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា




៣២.កាលពីថ្ងៃចន្ទ ៣កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣១ ខែមីនា គ.ស.២០២៥ នៅសាកលវិទ្យាល័យពាណិជ្ជសាស្ត្រ អេស៊ីលីដា ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ខី តាឃី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានរបស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា លោក សាយ សុខខេង ទីប្រឹក្សាបច្ចេកទេសរបស់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា អមដោយ លេខាធិការដ្ឋាន បានចូលរួមពិនិត្យនិងវាយតម្លៃក្នុងការទទួលស្គាល់សាកលវិទ្យាល័យពាណិជ្ជសាស្ត្រ អេស៊ីលីដា ជាគ្រឹះស្ថានបណ្តុះបណ្តាល កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។

រៀបចំដោយ ÷ **លោក ឡាយ វិចិត្រ**

សម្របសម្រួលអត្ថបទ ÷ **កញ្ញា សុខ ណារី**